# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ ២០៥៥ សហវ.ឆ

រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែ មករា ឆ្នាំ ២០០៣

## សូមជំរាបមក

- ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកអភិបាលរាជធានីភ្នំពេញ ក្រុងកែប និងក្រុងប៉ៃលិន
- ឯកឧត្តមអភិបាលគ្រប់ខេត្ត ក្រុង

**កម្មវត្ថុ** : ស្តីពីការរៀបចំគំរោងថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ ។

**យោង** : - យោងតាមជំពូកទី ៧ នៃច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស / រកម / ០៣០១ / ០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១

- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- លិខិតលេខ ០០១ គ.ឃ.ស ចុះថ្ងៃទី ០៩ ខែ មករា ឆ្នាំ ២០០៣ របស់គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់ សំណើរៀបចំសេចក្តីណែនាំ អំពី ការរៀបចំថវិកាឃុំ សង្កាត់ សំរាប់ឆ្នាំថវិកា ២០០៣ ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជំរាបជូនឯកឧត្តមមេត្តាជ្រាបថា ÷ ចំពោះដំណើរការរៀបចំថវិកាឃុំ សង្កាត់ប្រចាំឆ្នាំ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុបានចេញប្រកាសណែនាំលេខ ៣៣១ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការអនុវត្តថវិកាឃុំ សង្កាត់ និងបានផ្សព្វផ្សាយដល់គ្រប់ខេត្ត ក្រុង និងគ្រប់ឃុំ សង្កាត់រួចហើយ ។ បន្ថែមលើនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមផ្តល់នូវគំរូណែនាំលំអិតចំនួនពីរទៀត ដែលពាក់ព័ន្ធនឹងដំណើរការរៀបចំគំរោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ដូចមានជូនភ្ជាប់ជាមួយលិខិតនេះ :

១. គំរូលិខិតជូនដំណឹង ស្តីពីការបញ្ជាក់ទទួលស្គាល់លើគំរោងថវិការបស់ឃុំ សង្កាត់ ( សំរាប់សាលាខេត្ត ក្រុង )

២. គំរូអនុសារណៈ ស្តីពីការរៀបចំគំរោងថវិកាប្រចាំឆ្នាំរបស់ឃុំ សង្កាត់ ( សំរាប់មេឃុំ ចៅសង្កាត់ ) ។

អាស្រ័យហេតុនេះ សូមឯកឧត្តមមេត្តាជ្រាប និងជូនដំណឹងអោយបានរួសរាន់ ដល់គ្រប់ឃុំ សង្កាត់នៃខេត្ត ក្រុងសាមី តាមការគួរ ។

សូមឯកឧត្តមទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់ពីខ្ញុំ ។

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

ចម្លងជូន :

- គណៈកម្មាធិការជាតិគាំទ្រឃុំ សង្កាត់
- ក្រសួងមហាផ្ទៃ

( ដើម្បីជូនជ្រាប )

- គ្រប់មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ក្រុង
- គ្រប់រតនាគារខេត្ត ក្រុង

( ដើម្បីមុខការ )

- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមហាផ្ទៃ

សាលាខេត្ត ក្រុង.........

លេខ :.............

.............ថ្ងៃទី ខែ ឆ្នាំ ២០០...

## ប្រតិភូរាជរដ្ឋាភិបាល... ឬអភិបាលខេត្ត ក្រុង...

## ជំរាបមក

## លោកប្រធានក្រុមប្រឹក្សាឃុំ សង្កាត់.....

**កម្មវត្ថុ** : ស្តីពីការទទួលស្គាល់គំរោងថវិកាឆ្នាំ ២០០... របស់ឃុំ សង្កាត់.......... ។

**យោង** : - ..........................................................................

- ព្រះរាជក្រមលេខ នស / រកម / ០៣០១ / ០៥ ចុះថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០០១ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- អនុក្រឹត្យលេខ ២៦ អនក្រ.បក ចុះថ្ងៃទី ០២ ខែ មេសា ឆ្នាំ ២០០២ ស្តីពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុឃុំ សង្កាត់
- ប្រកាសលេខ ៣២៩ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២ ស្តីពីទំរង់ និងមាតិកាថវិកាឃុំ សង្កាត់
- ប្រកាសលេខ ៣៣១ សហវ.ប្រក ចុះថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០២ ស្តីពីការរៀបចំ និងការអនុវត្តថវិកាឃុំ សង្កាត់
- កំនត់ហេតុប្រជុំពិភាក្សាអនុម័តលើគំរោងថវិកាឆ្នាំ ២០០...របស់ក្រុមប្រឹក្សាឃុំ សង្កាត់....... ...ចុះថ្ងៃទី .....ខែ........ ឆ្នាំ ២០០... ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបជូនលោកប្រធានថា ÷ ខ្ញុំយល់ព្រមទទួលស្គាល់គំរោងថវិកាឆ្នាំ២០០... របស់ឃុំ សង្កាត់......ស្ថិតក្នុងស្រុក ខ័ណ្ឌ.......ដែលមានចំនូលសរុបចំនួន.........រៀល(សរសេរជាអក្សរ...) ក្នុងនោះ : ចំនូលកាតព្វកិច្ច ដែលឃុំ សង្កាត់ត្រូវប្រមូលមានចំនួន : .......….រៀល និងចំនូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់មានចំនួន : .........រៀល និងគណទានចំនាយសរុបចំនួន : ........រៀល (សរសេរជាអក្សរ...) ដូចមានរាយលំអិតក្នុងតារាង តាមទំរង់ និងមាតិកាថវិកាឃុំ សង្កាត់ ជូនភ្ជាប់ជាមួយនេះ ។

គំរោងថវិកានេះ មានប្រសិទ្ធភាពអនុវត្តចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ ២០០...តទៅ ។

អាស្រ័យហេតុនេះសូមលោកប្រធានជ្រាប និងទទួលនូវការរាប់អានពីខ្ញុំ ។

**ចម្លងជូន** :

**ហត្ថលេខា**

- ........................

( ដើម្បីជូនជ្រាប )

- មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្ត ក្រុង.......
- រតនាគារខេត្ត ក្រុង.......

( ដើម្បីមុខការ )

- ឯកសារ

# ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ខេត្ត ក្រុង........

ស្រុក ខ័ណ្ឌ..........

ឃុំ សង្កាត់............

## អនុស្សារណៈ

## ស្តីពីការរៀបចំគំរោងថវិកាឆ្នាំ n

## របស់ឃុំ សង្កាត់.....

## I. អំពីថវិកាចរន្ត

### ក. ចំនូលចរន្ត

**១.ចំនូលពន្ធមូលដ្ឋាន :** អនុវត្តឆមាសទី ១ ឆ្នាំ n-១ : ................រៀល ប៉ាន់ស្មានអនុវត្តឆ្នាំ n-១ :..........រៀល គំរោងឆ្នាំ n : ..........រៀល មានកំនើន......% (ឬថយចុះ.......% ) ក្នុងនោះ :

- ពន្ធ..........:
- ពន្ធ..........:
- ពន្ធ..........: អនុវត្តឆមាសទី ១ ឆ្នាំ n-១ : ........រៀល ប៉ាន់ស្មានអនុវត្តឆ្នាំ n-១ :.......រៀល គំរោងឆ្នាំ n : .... ...រៀល មានការកើនឡើងចំនួន......រៀល "ឬថយចុះចំនួន.......រៀល" ការកើនឡើង"ឬថយចុះ"នេះ អាស្រ័យដោយ : .... ......................" រៀបរាប់ពីហេតុផលជាមូលដ្ឋាននានា ដែលនាំអោយគ្រោងគិតតួលេខចំនូលនេះ " ។

**ឧទាហរណ៍:** ( ការរៀបរាប់ពីហេតុផល )

- <u>ពន្ធលើដីធ្លីមិនបានប្រើប្រាស់</u> : ទំហំដីដែលត្រូវប្រមូលពន្ធក្នុងឆ្នាំ n-១ មានចំនួន ១០០ហិកតា នៅឆ្នាំ n ទំហំដីដែលត្រូវប្រមូលពន្ធមានចំនួន ៨០ហិកតាតែប៉ុណ្ណោះ ព្រោះនៅឆ្នាំ n ផ្ទៃដីចំនួន ២០ហិកតា នឹងចាប់ផ្តើមធ្វើការដាំដុះ ឬបង្កបង្កើនផលស្រូវ ឬប្រើប្រាស់ជាកសិដ្ឋានចិញ្ចឹមសត្វ ..... ដែលមិនត្រូវបានជាប់ពន្ធទៀតឡើយ ។
- <u>ពន្ធលើមធ្យោបាយដឹកជញ្ជូន និងយានយន្តគ្រប់ប្រភេទ</u> : ក្នុង ឆ្នាំ n-១ ស្ថិតិយានយន្តដែលត្រូវប្រមូលពន្ធរួមមាន : ម៉ូតូចំនួន........គ្រឿង រថយន្តតូច.........គ្រឿង រថយន្តធំ.......គ្រឿង ..... នៅឆ្នាំ n គ្រោងកំនើនយានយន្តចំនួន ១០% ដូច្នេះពន្ធដែលត្រូវប្រមូលមានចំនួន.........រៀល ក្នុងនោះ :

    + ម៉ូតូ : ៣ ០០០៛ x ... គ្រ = ............៛

    + រថយន្តតូច : ៨០ ០០០៛ x ... គ្រ = ............៛

.............................................

**២. ចំនូលមិនមែនសារពើពន្ធ :** អនុវត្តឆមាសទី ១ ឆ្នាំ n-១ : ........រៀល ប៉ាន់ស្មានអនុវត្តឆ្នាំ n-១ :.......រៀល គំរោងឆ្នាំ n : ..........រៀល មានកំណើន......% (ឬថយចុះ.......% ) ក្នុងនោះ :

- កំរៃរដ្ឋបាល : ចំនូលពីថ្លៃជាវក្រដាសអត្រានុកូលដ្ឋានគ្រប់ប្រភេទ................
- ការបង់ប្រាក់របស់អ្នកប្រើប្រាស់សេវាកម្មមូលដ្ឋាន : ចំនូលពីសេវាកម្មនានា........
- ចំនូលពីទ្រព្យសម្បត្តិរបស់ឃុំ សង្កាត់ : ថ្លៃឈ្នួលអចលនៈទ្រព្យ..........

( រៀបរាប់តាមលំនាំខាងលើ ទៅតាមលក្ខណៈនៃមុខចំនូលនីមួយៗ ) ។

**៣.ចំនូលពីការផ្ទេររបស់មូលនិធិឃុំ សង្កាត់សំរាប់រដ្ឋបាលទូទៅ** : យោងតាមលិខិត ( ជូនដំណឹង ) លេខ ....ចុះថ្ងៃទី .... ខែ ...ឆ្នាំ ..... របស់ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ( ឬរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ) នៅឆ្នាំ n ឃុំ សង្កាត់ ... នឹងទទួលបានការវិភាជន៍ធនធានពីមូលនិធិឃុំ សង្កាត់ចំនួន ........៛ សំរាប់ចំនាយរដ្ឋបាលទូទៅចំនួន ........ ..៛ និងសំរាប់ចំនាយ វិនិយោគផ្នែករដ្ឋបាលចំនួន ..........៛ ។

**៤.ចំនូលពីការអនុវត្តមុខងារជាភ្នាក់ងារ :** ផ្អែកតាមកិច្ចសន្យា (ឬកិច្ចព្រមព្រៀង ) ចុះថ្ងៃទី ខែ..... ឆ្នាំ..... ជាមួយឯកឧត្តមរដ្ឋមន្ត្រីក្រសួង .....ឬឯកឧត្តមអភិបាលខេត្ត ក្រុង ....ឬលោកប្រធានមន្ទីរ .......ឬ .......នៅឆ្នាំ n ឃុំ សង្កាត់ត្រូវទទួលបានថវិកាចំនួន ......៛ សំរាប់រៀបចំ .....ឬជួសជុល ........ឬផ្សព្វផ្សាយកម្មវិធី .......នៅក្នុងភូមិ .....ឬក្នុងឃុំ សង្កាត់ទាំងមូល ។

**៥.ចំនូលចរន្តផ្សេងៗ :** អនុវត្តឆមាសទី ១ ឆ្នាំ n-១ : ........រៀល ប៉ាន់ស្មានអនុវត្តឆ្នាំ n-១ :.......រៀល គំរោងឆ្នាំ n : .......រៀល ក្នុងនោះ :

- ចំនូលពី ..........: ..........
- ចំនូលពី ..........: ..........

( រៀបរាប់តាមលំនាំខាងលើ ឬបញ្ជាក់ពីសកម្មភាព ឬហេតុផលនានា ពាក់ព័ន្ធនិងការប្រមូលចំនូលនេះ ) ។

## ខ. ចំណាយចរន្ត

**១.ចំណាយបៀវត្សនិងប្រាក់ចំណាត់**

- បុគ្គលិកមន្ត្រីរដ្ឋបាល : .........៛/នាក់/ខែ X.....នាក់ X ១២ ខែ = ............៛

  ......................

- បុគ្គលិកសេវាមូលដ្ឋាន : .........៛/នាក់/ខែ X.....នាក់ X ១២ ខែ = ............៛

  ......................

- ប្រាក់បំនាច់ក្រុមប្រឹក្សាឃុំ សង្កាត់: សរុប ..........៛ ក្នុងនោះ :
  + មេឃុំ ចៅសង្កាត់ : ១០០ ០០០ ៛/នាក់/ខែ X ១នាក់ X ១២ ខែ = .............៛

+ ជំទប់ ឬចៅសង្កាត់រង : ៨០ ០០០ ៛/នាក់/ខែ X ២នាក់ X ១២ ខែ = ............ ៛

+ សមាជិកផ្សេងៗទៀត : ៧០ ០០០ ៛/នាក់/ខែ X.....នាក់ X ១២ ខែ = ............៛

**២.ចំណាយរដ្ឋបាលទូទៅ**

- ថ្លៃជួលការិយាល័យ : ............៛/ខែ X ១២ ខែ = ............៛
- ជួសជុលនិងថែទាំ ( ប្រភេទជួសជុលតូច) :
  + ជួសជុលរបងសាលាឃុំ សង្កាត់ :.............
  + ជួសជុលទ្វារ បង្អួច និងលាបថ្នាំថ្មីអាគារសាលាឃុំ សង្កាត់ :
- ទឹក ភ្លើង ....
  + ទឹក : .........៛/ $m^3$ X .....$m^3$/ខែ X ១២ ខែ = ............៛
  + ភ្លើង : .........៛/KW X ..... KW /ខែ X ១២ ខែ = ............៛

...........................

..............................

**៣.ចំណាយសេវាសាធារណៈ**

- ជួសជុលថែទាំ :
  + ជួសជុលទំនប់ទឹកប្រវែង ១០០ ម៉ែត្រ : ............
  + ជួសជុលរថយន្តប្រមូលសំរាម : .................

....................................

- ផ្គត់ផ្គង់សេវា : ..........
- ចំនាយផ្សេងៗ : ...........

**៤.ចំណាយសំរាប់មុខងារជាភ្នាក់ងារ**

- មុខងារជាភ្នាក់ងារប្រគល់ដោយរដ្ឋ : .............
- មុខងារជាភ្នាក់ងារប្រគល់ដោយថ្នាក់ក្រសួង ស្ថាប័ន : ...........
- មុខងារជាភ្នាក់ងារប្រគល់ដោយថ្នាក់ខេត្ត ក្រុង : ..........
- មុខងារជាភ្នាក់ងារដ៏ទៃទៀត : ..........

បរិយាយពីកិច្ចការនីមួយៗ ដែលឃុំ សង្កាត់ត្រូវអនុវត្តជំនួសក្រសួង ស្ថាប័ន ខេត្ត ក្រុង ឬ.........។

**៥.ចំណាយអន្តរាគមន៍ផ្នែកសង្គមកិច្ច**

- ជួយដល់ក្រុមគ្រួសារ : បញ្ជាក់ពីចំនួនគ្រួសារក្រីក្រ ឬរងគ្រោះដោយគ្រោះធម្មជាតិ និងចំនួនទឹកប្រាក់ត្រូវផ្តល់អោយក្នុងមួយគ្រួសារ.......

-ឧបត្ថម្ភធនដល់អង្គការមូលដ្ឋាន : ការផ្ដល់ថវិកាគាំទ្រដល់សហគមន៍ក្នុងមូលដ្ឋានដោយ បញ្ជាក់ពីចំនួនថវិកាទៅតាមគោលដៅនីមួយៗ ក្នុងការផ្ដល់ជំនួយនេះ ។

**៦.ចំណាយអន្តរាគមន៍ផ្នែកសេដ្ឋកិច្ច :**

- បរិមាណស្រូវពូជ x តំលៃឯកតា = ............សំរាប់ជួយជនរងគ្រោះក្នុងឃុំ សង្កាត់ចំនួន.........ឬសំរាប់ជួយដល់ឃុំ សង្កាត់ចំនួន.........ដើម្បីបង្កើនទិន្នផលស្រូវ ឬ............

- រៀបរាប់ពីការចំណាយផ្សេងៗទៀត ដែលពាក់ពន្ធ័ដល់ការងារជំរុញកិច្ចអភិវឌ្ឍន៍សេដ្ឋកិច្ចក្នុងឃុំ សង្កាត់( ប្រសិនមាន)

**៧.ចំណាយមិនបានគ្រោងទុក :**

ថវិកាសរុប $x \leqslant 3\% =$ .........រ

## គ. អតិរេកថវិកាចរន្ត

បញ្ជាក់ : អតិរេកថវិកាចរន្តកើតមាន ក្នុងករណីផលដកនៃ ( ចំនួលចរន្ត - ចំណាយចរន្ត ) ជាចំនួនវិជ្ជមាន"

ចំនួលចរន្ត - ចំណាយចរន្ត = .............រ

# II.អំពីថវិកាមូលធន

## ក. ចំនួលមូលធន

**១.អតិរេកពីផ្នែកថវិកាចរន្ត :** បានមកពី : ចំនួលចរន្ត - ចំណាយចរន្ត = ..........រ

**២.ចំនួលពីមូលនិធិបំរុង :** ផ្អែកលើលទ្ធផលបិទបញ្ជីថវិកាឆ្នាំ n-២ ឃុំ សង្កាត់មានអតិរេកថវិកាចំនួន ........... រ ហើយចំនួនថវិកានេះ ក្រុមប្រឹក្សាឃុំ សង្កាត់បានអនុម័តកត់ត្រាបញ្ចូលទៅក្នុងគំរោងថវិកាឆ្នាំ n ដើម្បីជាប្រយោជន៍ដល់ការចំណាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ។

**៣.ចំនួលពីការផ្ទេរបស់មូលនិធិឃុំ សង្កាត់សំរាប់អភិវឌ្ឍន៍មូលដ្ឋាន :** យោងលិខិត( ជូនដំណឹង) លេខ....ចុះថ្ងៃទី .... .. ខែ ..ឆ្នាំ ... របស់ក្រុមប្រឹក្សាភិបាលមូលនិធិឃុំ សង្កាត់ ( ឬរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ) នៅឆ្នាំ n ឃុំ សង្កាត់នឹងទទួលបានការវិភាជន៍ធនធានពីមូលនិធិឃុំ សង្កាត់ចំនួន ..........រ សំរាប់ចំនាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ។

**៤.ចំនួលពីការរួមចំណែករបស់ប្រជាជនមូលដ្ឋានទៅក្នុងតំលៃគំរោង :** អនុវត្តឆមាសទី ១ ឆ្នាំ n-១ បានចំនួន:.....រៀល ប៉ាន់ស្មានអនុវត្តឆ្នាំ n-១ :.....រៀល ស្មើនឹង.......% នៃគំរោងប្រចាំឆ្នាំ បើប្រៀបធៀបនឹងតំលៃគំរោងសរុបការចូលរួមនេះ ស្មើនឹង.......% ។ សំរាប់ឆ្នាំ n តំលៃគំរោងសរុបមានចំនួន: ........រៀល ក្នុងនោះតំលៃគំរោងដែលប្រជាជនត្រូវចូលរួមមានចំនួន X រ ។ ដូចនេះឆ្នាំ n ចំនួនទឹកប្រាក់ដែលប្រជាជនត្រូវចូលរួមក្នុងតំលៃគំរោងគឺ X x ...% =....... រ ។

**៥.ចំនួលមូលធនផ្សេងៗ :**

- ចំនួលពីការលក់ទ្រព្យសម្បត្តិ : ...( រៀបរាប់ពីទ្រព្យសម្បត្តិនីមួយៗ ដែលគ្រោងលក់នៅឆ្នាំ n និងតំលៃប៉ាន់ស្មាន )

- ចំនូលពីអំនោយ :....( ផ្អែកតាមការសន្យារបស់សប្បុរសជននានា ក្នុងនិងក្រៅប្រទេស ឬការគ្រោងធ្វើចលនាផ្សេងៗ ដែលបំផុសអោយមានការចូលរួមពីសប្បុរសជន ដើម្បីជាប្រយោជន៍ដល់ឃុំ សង្កាត់ )
- ចំនូលផ្សេងៗ :....( ចំនូលពីប្រភពផ្សេងៗទៀតក្រៅពីការរៀបរាប់ខាងលើ ដែលអាច ឬនឹងកើតមាន ) ។

## ខ. ចំនាយមូលធន

### ១.ចំនាយវិនិយោគផ្នែករដ្ឋបាល

- ទិញទ្រព្យសម្បត្តិ : រៀបរាប់តាមប្រភេទទ្រព្យសម្បត្តិនីមួយៗដែលគ្រោងទិញ អំពីចំនួន និងតំលៃឯកតាគ្រោងគិត ។
  ឧទាហរណ៍: ទិញម៉ូតូពីរគ្រឿងបំរើអោយផ្នែករដ្ឋបាល : ៨០០$/គ្រ x ៣ ៩០០៛/$ x ២គ្រ =...........៛
- សាងសង់ ឬការងារ : បញ្ជាក់ពីទំហំអាគារដែលត្រូវសាងសង់ មានប៉ុន្មានជាន់ ប៉ុន្មានម៉ែត្រការ៉េ និងតំលៃប៉ាន់ស្មានក្នុងមួយម៉ែត្រការ៉េ ឬតំលៃសរុប ដោយភ្ជាប់គំរោងប្លង់ បញ្ជីប៉ាន់តំលៃសំភារៈសំនង់ និងពលកម្ម ......
- ទព្វសំភារៈ : លំអិតពីចំនួន តំលៃឯកតា ទៅតាមប្រភេទទព្វសំភារៈ គ្រឿងសង្ហារិមនីមួយៗ សំរាប់បំពាក់អោយសំនង់ ឬទិញឧបករណ៍ សំភារៈការិយាល័យសំរាប់ប្រើប្រាស់ កុំព្យូទ័រ ទូរដាក់ឯកសារ .........
- ផ្សេងៗ : បញ្ជាក់ពីចំណាយបន្ទាប់បន្សំផ្សេងៗ ដែលពាក់ព័ន្ធនឹងចំនុចទាំងបីខាងលើនេះ ។

### ២.ចំនាយវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន

- ទិញសំភារៈ : ......
- សាងសង់អាគារ : .........
- ទព្វសំភារៈ : .........
- ផ្សេងៗ : .........

រៀបរាប់តាមលំនាំចំនុច ១ ខាងលើ ចំពោះការចំនាយពាក់ព័ន្ធនឹងវិនិយោគអភិវឌ្ឍន៍មូលដ្ឋាន ទៅតាមមុខសញ្ញាចំនាយនីមួយៗ ។

គំរោងថវិកាខាងលើនេះ បានរៀបចំឡើងដោយគណកម្មាធិការកសាងផែនការ និងថវិកា និងមានការចូលរួមពីសាធារណៈជនក្នុងឃុំ សង្កាត់ចំនួន.......នាក់ កាលពីថ្ងៃទី....ខែ..........ឆ្នាំ ..... ។ រីឯការចំនាយអភិវឌ្ឍន៍មូលដ្ឋាន គឺបានរៀបចំឡើងផ្អែកតាមផែនការអភិវឌ្ឍន៍របស់ឃុំ សង្កាត់ ឆ្នាំ ២០០...- ២០០... (និងផ្អែកតាមការចាំបាច់ចំពោះមុខដែលឃុំ សង្កាត់កំពុងប្រឈម ........) .........។

...........ថ្ងៃទី ខែ ឆ្នាំ ២០០...

ហត្ថលេខានិងត្រា

មេឃុំ ចៅសង្កាត់